**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃពុធ ៤រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤

**២. ទីកន្លែង ៖** នៅបន្ទប់ "ខ" អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៥រូប និងតាមប្រព័ន្ធនិម្មិតចំនួន២៥រូប សរុបចំនួន៦០រូប។

**៤. របៀបវារៈ៖**

៤-១- មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤-២- បទបង្ហាញស្តីពី លទ្ធផល ឧបសគ្គ និងបទពិសោធន៍ ក្នុងការជំរុញមកទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ ដើម្បីសម្រេចគោលដៅ៩៥ទីមួយ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ បង្ហាញដោយ **លោកស្រី សៀង សុវត្ថិទេវី** ប្រធានកម្មវិធីអេដស៍ នៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។

៤-៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំ និងបានបញ្ជាក់ថា ជំងឺអេដស៍នៅតែជាចំណុចអាទិភាព ជាទិសដៅគួរឱ្យបារម្ភគឺ គោលដៅ៩៥ទីមួយ ដែលមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។ ហេតុដូច្នេះ តើយើងគួររកវិធីសាស្ត្រ ឬមធ្យោបាយយ៉ាងណា ដើម្បីសម្រេចគោលដៅ៩៥ទីមួយ នៅឆ្នាំ២០២៥។ បទអន្តរាគមន៍បង្ការដែលមានលក្ខណៈសុក្រឹតជាក់លាក់ក្នុងការយកមកប្រើប្រាស់ ដើម្បីសម្រេចបាននូវការសម្រេចចិត្តបានត្រឹមត្រូវ និងទាន់ពេលវេលា ដែលផ្តោតទៅលើគោលនយោបាយលុបបំបាត់ការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍សម្រេចគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

កិច្ចប្រជុំនេះបានផ្តោតលើការពិនិត្យលើបទពិសោធន៍ ក្នុងអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានីភ្នំពេញ។

បទបង្ហាញស្តីពី បទពិសោធន៍នៃការអនុវត្តការងារនេះ បង្ហាញដោយ **លោកស្រី សៀង សុវត្ថិទេវី** ប្រធានកម្មវិធីអេដស៍ នៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។

ជាលទ្ធផលលោកស្រី បានបង្ហាញថា យន្តការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ រដ្ឋបាលរាជធានីភ្នំពេញបានរៀបចំមាន៖

- រចនាសម្ព័ន្ធការគ្រប់គ្រងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ មានដូចជាគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខណ្ឌទាំង១៤ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សង្កាត់:៥៥សង្កាត់ (៧ខណ្ឌ) និងមានអង្គការដៃគូចំនួន៨ ធ្វើការជាមួយក្រុមប្រជាជនគន្លឹះ ព្រមទាំងមានអង្គការចំនួន៣ ធ្វើការជាមួយអ្នកផ្ទុកមេរោគអេដស៍។
- រៀបចំផែនការយុទ្ធសាស្ត្រ ដែលក្នុងនោះមានផែនការសំខាន់ៗដូចជា៖ រៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីពន្លឿនការសម្រេចបានគោលដៅបញ្ចប់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ (FTCI)មាន៖ ៥គោលបំណង ១៩យុទ្ធសាស្ត្រ និងផែនការសកម្មភាពអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សំរាប់ឆ្នាំ២០២៣ ចំនួន១៧សកម្មភាព ផ្តោតលើការផ្សព្វផ្សាយ ប្រជុំសម្របសម្រួល និងការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមូលដ្ឋាន ។

លោកស្រីបានបញ្ជាក់ថា តាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រ នៅរាជធានីភ្នំពេញក្នុងឆ្នាំ២០២៣ មានអ្នកផ្ទុកមេរោគអេដស៍ ចំនួន២០ ៩៥២នាក់។ តាមលទ្ធផលនៃការអនុវត្តការឆ្លើយតប

នឹងមេរោគអេដស៍ និងជំងឺអេដស៍ បានបង្ហាញថា មានអ្នកផ្ទុកមេរោគអេដស៍ ចំនួន២៤ ២០៧នាក់ បានដឹងពីស្ថានភាពរបស់ខ្លួន ដែលក្នុងចំណោមនោះមានអ្នកទទួលបានការព្យាបាលចំនួន២៤ ២០១នាក់ និងអ្នកបានធ្វើតេស្តរាប់ចំនួនមេរោគក្នុងឈាម (Viro-load test) មានចំនួន២០ ១៦៦នាក់ ។

ទន្ទឹមនឹងការទទួលលទ្ធផលល្អខាងលើ លោកស្រីបានលើកឡើងថា ពីបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារនេះផងដែរដូចជា៖

- អត្រាប្រេវ៉ាឡង់ និងអត្រាឆ្លងថ្មីនៃមេរោគអេដស៍ នៅតែមានកំរិតខ្ពស់ក្នុងចំណោមក្រុមប្រឈមមុខ។
- បទអន្តរាគមន៍បង្ការលើក្រុមប្រឈមមុខគ្របដណ្តប់បានតែ៦១,៩% ។
- ទីតាំងជួបក្រុមគោលដៅជាទីតាំងពិបាកក្នុងការផ្តល់ការអប់រំ ធ្វើតេស្តឈាម និងរក្សាការសម្ងាត់ តាមសួនច្បារ ទីសាធារណៈ និងម្ចាស់សេវាតាមក្លឹបកម្សាន្តមិនបានសហការពេញលេញ ដោយមិនអនុញ្ញាតិឲ្យចូលធ្វើការអប់រំ ឬធ្វើតេស្តនៅក្នុងគ្រឹះស្ថានសេវាកម្សាន្ត។
- ក្រុមគោលដៅលាក់មុខ (High Class (MSM)) មិនហ៊ានជួបផ្ទាល់ក្រុមការងារដើម្បីទទួលយកសារអប់រំ ឬតេស្តរកមេរោគអេដស៍ និងស្វាយ។
- មានការលាឈប់ និងការជ្រើសរើសបុគ្គលិក ជាពិសេសថ្មីៗ ដូច្នេះពួកគេមិនទាន់មានលទ្ធភាពធ្វើតេស្តរកមេរោគអេដស៍ ធ្វើអោយលទ្ធផលនៃការធ្វើតេស្តមិនសម្រេចបានតាមផែនការ។
- ពិបាកតាមរកដៃគូក្រុមប្រឈមមុខខ្ពស់ រួមទាំងករណីឆ្លង។
- ការទទួលបានសេវាលេបថ្នាំបង្ការជាមុន នៅពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (សេវា PrEP) នៅមានកម្រិតទាប។
- ធនធានមនុស្សមានការខ្វះខាតដូចជា ការផ្លាស់ប្តូរបុគ្គលិក ការលាឈប់ ចូលនិវត្តន៍។ល។

លោកស្រីបានលើកឡើងផងដែរថា ការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានលទ្ធផលនេះ ក៏ដោយសារការខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាល ដែលមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋបាលរាជធានីភ្នំពេញ អង្គការជាដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ក្នុងការដាក់ចេញនូវបទអន្តរាគមន៍នានា និងអនុវត្តការឆ្លើយតបនេះឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ក៏ដូចជាតាមរយៈនៃការវិភាជន៍ថវិកាជាតិ។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំមានប្រសាសន៍ថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិដែលរួមមាន

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេសថ្លែងនូវអំណរគុណ និងជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបនឹងពុទ្ធពរបួនប្រការ កុំបីឃ្លាតឡើយ។

សម្រាប់កិច្ចប្រជុំលើកទី៣នឹងកំណត់យកនៅថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)៕

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤

**បានយើញ និងឯកភាព**
**ប្រធានអង្គប្រជុំ**

បណ្ឌិត ឈឹម ឃិនដារ៉េត

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**វេជ្ជ. ហួត សេរីវង្ស**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**